# កុម្មាសបិណ្ឌិជាតក



ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

រៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ
**កុល ផេង**

ព.ស. ២៥៦៤

# កុម្មាសបិណ្ឌិជាតក

រៀបរៀងដោយ

បណ្ឌិត **កុល ផេង**

សីល  សមាធិ  បញ្ញា

ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស. ២៥៦៤

*ឈ្មោះសៀវភៅ* **កុម្មាសបិណ្ឌិជាតក**

*រៀបរៀងដោយ* បណ្ឌិត **កុល ផេង**

ប្រធានពុទ្ធិកបណ្ឌិត្យសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

*ទីតាំងធ្វើ* ពុទ្ធិកបណ្ឌិត្យសភា

*ការផ្សាយ* របស់ពុទ្ធិកបណ្ឌិត្យសភា

*រក្សាសិទ្ធិ* ពុទ្ធិកបណ្ឌិត្យសភា

*កាលបរិច្ឆេទ* ថ្ងៃសុក្រ ៥រោច ខែអស្សុជ

ឆ្នាំថោះ បញ្ចស័ក

ព.ស.២៥៦៥

ច.ល. ១៣៨៣

ម.ស. ១៩៤៣ ត្រូវនឹងថ្ងៃ

ទី៣ ខែវិច្ឆិកា គ.ស.២០២៣

# កុម្មាសបិណ្ឌិជាតក

**អធិបតី ក្នុងការរៀបរៀង**

**បណ្ឌិត ក្រុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**

*លោកគ្រូធម្មាចារ្យ* **ឃួយ ម៉ាន់ថន**

*លេខាធិការពុទ្ធិកបណ្ឌិត្យសភានៃ*

*សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

# រចនាសម្ពន្ធពុទ្ធិកបណ្ឌិត្យសភា
# នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
# ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

| | | |
|---|---|---|
| *បណ្ឌិត* | **ភុល ផេង** | *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា* |
| *សម្តេច* | **យ៉ន សេងយៀត** | *សមាជិក* |
| *ព្រះមហា* | **សុន្ទរ៍ សាមៀន** | *សមាជិក* |
| *ព្រះមហា* | **គូ សុភាព** | *សមាជិក* |
| *ឯកឧត្តមបណ្ឌិត* | **ឃី សុវណ្ណរតនា** | *អនុប្រធាន* |
| *បណ្ឌិត* | **ជា សានចាន់ថន** | *សមាជិក* |
| *បណ្ឌិត* | **ប៉ក់ ថាវិន** | *សមាជិក* |
| *សាស្ត្រាចារ្យ* | **ម៉ក់ វ៉ាន់** | *សមាជិក* |
| *ព្រឹទ្ធាចារ្យ* | **ហេង  គឹមហោ** | *សមាជិក* |
| *សាស្ត្រាចារ្យ* | **រស់  សាវេន** | *សមាជិក* |
| *សាស្ត្រាចារ្យ* | **ឌិត ជន** | *សមាជិក* |
| *សាស្ត្រាចារ្យ* | **ជា ក្រិស្នា** | *សមាជិក* |
| *សាស្ត្រាចារ្យ* | **អ៊ុង សុវណ្ណា** | *សមាជិក* |
| *ព្រឹទ្ធាចារ្យ* | **ដាំ ភុយ** | *សមាជិក* |
| *លោកគ្រូជម្មានន្ទ* | **វ៉ាន់ ចាន់សារ៉ែន** | *អគ្គលេខាធិការ* |

# ឧត្តមក្រុមប្រឹក្សា

*សម្តេច* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិត្យសភា*

*សម្តេច* **យ៉ន សេងយៀត** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិត្យសភា*

*ព្រះរាជបុត្រី* **នរោត្តម អរុណរស្មី**

*ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិត្យសភា*

*មហាឧបាសិកា* **កុល គីម ផល្លា**

*ជា អគ្គពុទ្ធសាសនូបត្ថម្ភិកធរជោតិកា*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

| | | |
|---|---|---|
| *បណ្ឌិត* | **កុល ផេង** | *អធិបតីក្រុមជំនុំ* |
| *សម្តេច* | **យ៉ន សេងយៀត** | *សមាជិក* |
| *ព្រះអង្គគ្រូ* | **ពេញ វិបុល** | *សមាជិក* |
| *ព្រះអង្គគ្រូ* | **គូ សុភាព** | *សមាជិក* |
| *ព្រះអង្គគ្រូ* | **គ្រឿង ព្រឹម** | *សមាជិក* |
| *ឯកឧត្តមបណ្ឌិត* | **ឃី សុវណ្ណរតនា** | *សមាជិក* |
| *លោកគ្រូជម្ទាវ* | **វ៉ាន់ ចាន់សារ៉េន** | *សមាជិក* |
| *លោកគ្រូជម្ទាវ* | **គង់ សំអឿន** | *សមាជិក* |
| *ឯកឧត្តម* | **ផូស សុធា** | *សមាជិក* |

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

| | | |
|---|---|---|
| *លោកគ្រូជម្មានន្ទ* | **វ៉ាន់ ចាន់សារ៉ែន** | *ប្រធាន* |
| *លោកគ្រូ* | **ហួយ វ៉ាន់ថន** | *សមាជិក* |
| *លោកគ្រូ* | **សំ សុផល** | *សមាជិក* |
| *លោកគ្រូ* | **ចាន់ ហួ** | *សមាជិក* |
| *លោកគ្រូ* | **ហួយ វ៉ាន់ថន** | *សមាជិក* |
| *លោកគ្រូ* | **សំ សុផល** | *សមាជិក* |
| *លោកគ្រូ* | **ម៉ម ម៉ានិត** | *សមាជិក* |
| *លោកស្រី* | **សៅ ស្រីដែត** | *សមាជិក* |

# **បុព្វកថា**

***កុម្មាសបិណ្ឌិជាតក*** *ជាដំណើររឿងតំណាលពីបុព្វជាតិរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ កាលដែលព្រះអង្គ យោនយកកំណើតជា* ***ព្រះពោធិសត្វ*** *បានបំពេញទានត្រឹម នំកុម្មាស៤ដុំប៉ុណ្ណោះថ្វាយចំពោះព្រះបច្ចេកពុទ្ធ ៤ព្រះអង្គ ។ ដោយអនុភាពនៃបុណ្យនេះព្រះពោធិសត្វបានចែកឋានពីជាតិនោះមក។ លោកបានទៅចាប់កំណើតជាបុត្រានៃព្រះរាជាក្នុងដែនកាសីដែលមានផ្ទៃដីចំនួន៣០០យោជន៍ជាទីបំផុតក្នុងរាជសម្បត្តិ ក្នុងជាតិបន្ទាប់នោះតែម្តង។*

*ខ្ញុំព្រះករុណាខ្ញុំបាទ បានរៀបរៀង* ***សៀវភៅនេះឡើង*** *ក្នុងគោលបំណង ដូចខាងក្រោម៖*

*១- ជាជំនួយដល់ការយល់ដឹងបន្ថែមក្នុងការបំពេញទាន*

*២-បង្ហាញពីការធ្វើទានតិចតួចតែមានផល ដ៏អស្ចារ្យមហិមា មិនអាចកាត់ថ្លៃបាន*

*៣.-បង្ហាញពីការជ្រះថ្លាចំពោះ ព្រះសង្ឃទោះព្រះពុទ្ធទ្រង់បរិនិព្វានទៅហើយក្តី*

*៤-បង្ហាញដល់មនុស្សឱ្យចេះធ្វើទានឱ្យបានមុន ទើបចាំបរិភោគខ្លួនឯងតាមក្រោយ*

៥- ជាការផ្សព្វផ្សាយព្រះពុទ្ធសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យរឹតតែបានទូលំទូលាយ។

វិធីក្នុងការបកប្រែ ពុំបានលើកយកមេគោលបាលីក្នុងគាថា មកដាក់ ហើយ ទើបប្រែពន្យល់នោះទេ គឺប្រែយកសេចក្ដី ទាំងក្នុងបាលីគាថា ទាំងក្នុងសេចក្ដីអធិប្បាយនៃអដ្ឋកថា ឱ្យក្លាយជាភាសាខ្មែរ ល្មមស្ដាប់បានតែម្ដង។

**កុម្មាសបិណ្ឌិ**នេះ ទោះបីក្រុមជំនុំបានត្រួតពិនិត្យលើខ្លឹមសារ ន័យ សេចក្ដី អក្ខរៈ ឃ្លាល្បះ ដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នបំផុតក៏ដោយ ក៏គង់នៅសល់សេចក្ដីខុសឆ្គងខ្លះជាក់ជាពុំខាន។

យើងខ្ញុំ សូមអភ័យទោស អំពីសម្នាក់លោកអ្នកប្រាជ្ញ កវីបណ្ឌិត ព្រឹទ្ធាចារ្យ និងលោកអ្នកអាន ជាទីគោរពទាំងអស់ ដោយក្ដីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

ត្រង់ចំណុចនេះ យើងខ្ញុំបាននឹកឃើញនូវចំណាររបស់សម្ដេចព្រះមហាសុមេធាធិបតី **ជួន-ណាត ជោតញ្ញាណោ** មួយប្រយោគថា:

**"ធម្មតា ការងារអ្វីទាំងអស់ក្នុងលោក តែងតែមានភ្លាំងភ្លាត់ខ្លះ បើមិនច្រើន ក៏តិចតួចពុំខាន នេះជាទម្លាប់នៃការងាររបស់បុថុជ្ជន ព្រោះត្រូវ ជាគូគ្នានឹងខុស ប៉ុន្តែបើមានត្រូវច្រើន មានខុសតែបន្តិចបន្តួច ក៏គង់អាចប្រើការកើត គ្រាន់បើជាងគ្មានសោះទៅដែរ"។**

ជាទីអវសាន របស់បុព្វកថានេះ ដោយអានុភាពនៃកុសល ដែលកើតពីការខិតខំប្រឹងប្រែង ឱ្យបានចេញជាស្នាដៃ

ដ៏ប្រពៃនេះ យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសនូវអត្តមនុញ្ញផល ជូនចំពោះបុព្វបុរសខ្មែរ ដែលបានបូជាជីវិត ក្នុងបុព្វហេតុជាតិ សូមបានទៅកាន់សុគតិភព។

សូមអត្តមនុញ្ញផល មានដល់មាតាបិតា ជីដូនជីតា បងប្អូន ព្រមទាំងញាតិសាច់សាលោហិតទាំងអស់ ក្នុងសង្សារវដ្ត ទាំងអតីត: បច្ចុប្បន្ន និងអនាគត សូមមានសុខភាពល្អ អាយុយឺនយូរ កម្លាំងកាយមាំមួន ប្រាជ្ញាវាងវៃ កុំបីមានជំងឺតម្កាត់ មកបៀតបៀនយាយី ធ្វើទុក្ខបុកម្នេញឱ្យដល់សេចក្តីលំបាកតិចតួចឡើយ ហើយសូមបានជាឧបនិស្ស័យកំពូល គឺការរួចផុតចាកវដ្តទុក្ខ ដល់នូវបរមសុខ ពោលគឺព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ៥រោច ខែអស្សុជ ឆ្នាំថោះបញ្ចស័ក ព.ស.២៥៦៥
ភ្នំពេញថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ ២០២៣

**គុល ផេង**
ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

ដើម្បីបានរៀបរៀងចេញសៀវភៅមួយក្បាលនេះឡើងមក ដោយមានឧបការគុណ ពីលោកគ្រូធម្មាចារ្យ **ហួយ វ៉ាន់ថន** ជាលេខាធិការនៅ ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលលោកជាអ្នកស្វែងរកនៅគម្ពីរដើម ជាភាសាបាលី ហើយបានបកប្រែមកជាខេមរភាសា  ជាពិសេសភរិយារបស់គាត់ គឺឧបាសិកា **សៅ ស្រីដែត** ជាអ្នកជំនួយការស្រាវជ្រាវនៅពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលបានគូរគំនូរដ៏ស្រស់ស្អាតដាក់លើ គ្របសៀវភៅមួយក្បាលនេះធ្វើឱ្យមានភាពទាក់ដល់អ្នកអាន ។

ខ្ញុំក៏សូមអរគុណដល់ លោក **ម៉ម ម៉ានិត** ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យផ្សព្វផ្សាយទូលាយ និងជាប្រធានផ្នែកផ្សព្វផ្សាយ ប្រចាំសាកលវិទ្យាល័យបញ្ញាសាស្ត្រ ក្នុងការរៀបចំអក្សរខាងក្នុងឱ្យមានលំដាប់លំដោយរបៀបរៀបរយល្អងាយស្រួលដល់អ្នកអាន និងធ្វើជា អ្នករៀបចំសម្របសម្រួលខាងផ្នែកបោះពុម្ពឱ្យបានទាន់ ចែកជាធម្មទានដល់បុណ្យផ្កាប្រាក់សាមគ្គីនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រក្នុងថ្ងៃនេះ ។

# កុម្មាសបិណ្ឌិជាតក

## បុព្វនិទាន

ព្រះសាស្តាកាលស្តេចគង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីទាបក្រុងសាវត្ថី ព្រះបរមគ្រូនៃយើងប្រារព្ធព្រះនាងមល្លិកាទេវី ហើយ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា ន កិរត្ថិ ដូច្នេះជាដើម ។

## បច្ចុប្បន្ននិទាន

ពិតមែនហើយ ព្រះនាងមល្លិកាទេវីនោះ ជាធីតា របស់នាយមាលាការដែលជាប្រធាន នៅក្នុងនគរសាវត្ថី ព្រះនាងមានបុណ្យច្រើន ទ្រទ្រង់នូវរូបដ៏ឧត្តម ក្នុងកាល មានអាយុ ១៦ ឆ្នាំ ។ ថ្ងៃមួយ ព្រះនាងកាលទៅកាន់ បុប្ផារាម (សួនផ្កា) ជាមួយនឹងកុមារិកាទាំងឡាយ បាន កាន់យកនំកុម្មាស ៣ដុំ ដាក់ក្នុងកញ្ច្រែងផ្កា រៀបរយ ហើយក៏ទៅកាន់បុប្ផារាម។ កាលកំពុងចេញពីនគរ បាន

ឃើញព្រះមានព្រះភាគដែលបញ្ចេញព្រះរស្មីអំពីព្រះកាយទ្រង់មានភិក្ខុសង្ឃជាបរិវារ កំពុងចូលទៅក្នុងនគរ នាងក៏បង្អោននំកុម្មាសទាំង ៣ ថ្វាយ ។ ព្រះសាស្តាបង្អោនបាត្រដែលស្តេចចតុមហារាជថ្វាយ ទទួល (នំរបស់នាង) ។ ចំណែកនាងមល្លិកាថ្វាយបង្គំព្រះបាទាព្រះតថាគតហើយ កាន់យកបីតិដែលមានព្រះពុទ្ធជាអារម្មណ៍ ហើយឋិតនៅទីដ៏សមគួរមួយ ។ ព្រះសាស្តាសម្លឹងមើលនាង ទ្រង់ធ្វើការញញឹមហើយស្តេចយាងទៅ។ ព្រះអានន្ទដ៏មានអាយុសួរព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ជាហេតុនៃការញញឹមរបស់ព្រះតថាគត?" ។ លំដាប់នោះ ព្រះសាស្តាត្រាស់ហេតុនៃការញញឹមដល់ព្រះអានន្ទថា "ម្នាលអានន្ទ ដោយផលនៃដុំនំកុម្មាសទាំងនេះ កុមារិកានេះនឹងក្លាយជាអគ្គមហេសីរបស់ព្រះបាទកោសល ក្នុងថ្ងៃនេះឯង" ។

ចំណែកនាងកុមារិកាក៏ទៅកាន់បុប្ផារាម (សួនផ្កា) ។ ថ្ងៃនោះ ព្រះបាទកោសលធ្វើសង្គ្រាមជាមួយនឹងព្រះបាទអជាតសត្តុ ព្រះអង្គបរាជ័យ រត់គេចចេញពីសមរភូមិ ហើយឡើងជិះសេះ ធ្វើដំណើរមក ទ្រង់ឮសំឡេងច្រៀងរបស់នាង ទ្រង់មានព្រះទ័យប្រតិព័ទ្ធ ក៏បញ្ឆាឲ្យសេះបែរមុខទៅកាន់បុប្ផារាមនោះ ។ នាងមល្លិកាជាអ្នកដល់ព្រមដោយបុណ្យ បានឃើញព្រះរាជាហើយ  នាងនៅស្ងៀមមិនរត់គេចទៅណាឡើយ មិនត្រឹមតែប៉ុណ្ណោះនាងថែមទាំងយកដៃមកចាប់ខ្សែបង្ហៀរសេះរបស់ព្រះរាជាទាំងដែលព្រះរាជាកំពុងគង់នៅលើខ្នងសេះនោះឯង។ ឃើញដូច្នោះ ព្រះរាជាក៏សួរទៅកាន់នាងថា "នាងមានស្វាមីហើយ ឬនៅ?" នៅពេលទ្រង់ជ្រាបនូវភាពទំនេរមិនមានស្វាមីរបស់នាងហើយ ទ្រង់ក៏យាងចុះអំពីខ្នងសេះ ហើយក៏បណ្ដើរនាងទៅសម្រាកក្រោមដើមឈើមួយក្នុងបុប្ផារាមនោះ។ ទ្រង់ហត់នឿយព្រោះខ្យល់និងកម្ដៅ

ដោយទើបរត់គេចចេញពីសមរភូមិផង ទ្រង់ក៏ផ្ដំលក់មួយស្របក់ដោយយកភ្លៅរបស់នាងធ្វើជាខ្នើយ ។ បន្ទាប់ពីសម្រាកបានមួយស្របក់ ទ្រង់ក៏តើនឡើង ព្រះអង្គក៏ឲ្យនាងជិះលើខ្នងសេះទៅព្រះបរមរាជវាំងជាមួយ។ បន្ទាប់មកទ្រង់ក៏ចាត់ ពលសេនាជាបរិវារឱ្យជូននាងទៅគេហដ្ឋានរបស់ នាងវិញ។ ពេលរសៀលថ្ងៃនោះ ទ្រង់បានចាត់ឱ្យមហាមន្ត្រីបញ្ជូនបណ្ណាការនឹងរតនៈដ៏ច្រើនយកទៅកាន់គេហដ្ឋានលោកនាយមាលាការ។ បន្ទាប់មកមហាមន្ត្រីនាំនាងពីផ្ទះរបស់ត្រកូលមកកាន់ព្រះបរមរាជវាំង ហើយព្រះរាជាក៏ប្រទានការអភិសេកធ្វើជាអគ្គមហេសីក្នុងថ្ងៃតែមួយនោះឯង ។ ចាប់ពីពេលនោះមក ព្រះនាងបានជាទីស្រឡាញ់ពេញចិត្តរបស់ព្រះរាជា, ជាស្ត្រីដល់ព្រមដោយកល្យាណធម៌ទាំង ៥ មានៈ

១-បុព្វុដ្ឋាយិនី ជាស្ត្រីក្រោកមុនស្វាមី

២-បច្ឆានិបាតិនី ជាស្ត្រីចូលដំណេកក្រោយស្វាមី

៣-គិង្ការបដិស្សាវិធី ទទួលស្តាប់កិច្ចការអ្វីៗ ចាកអំពី
ស្វាមីដោយសេចក្តីមិនប្រមាទ

៤-មនាបចារិធី ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តស្វាមី

៥-បិយវាទិធី ពោលពាក្យជាទីស្រឡាញ់

ទន់ភ្លន់មិនត្រគោះបោកបោះ ចំពោះស្វាមីនោះនិង
ប្រតិបត្តិស្វាមីដូចជាទេវតា, ហើយព្រះនាងក៏ជាអ្នក
យកព្រះទ័យទុកដាក់ក្នុងការបូជាបម្រើព្រះសម្មាសម្ពុទ្ធ។
ភាពជាអ្នកបាននូវសម្បត្តិដោយសារ ការថ្វាយនំកុម្មាស
៣ ដុំរបស់ព្រះនាង បានផ្សព្វផ្សាយទៅទូទាំងសកល
នគរ ។

# រឿងកុម្មាសបិណ្ឌិ

ថ្ងៃមួយ ភិក្ខុទាំងឡាយគង់សន្ទនាគ្នាក្នុងសាលាធម្មសភាថា "ម្នាលអាវុសោទាំងឡាយ ព្រះនាងមល្លិកាទេវីថ្វាយនំកុម្មាស ៣ ដុំដល់ព្រះពុទ្ធ ក្នុងថ្ងៃនោះឯងក៏បានដល់នូវការអភិសេក ដោយផលនៃការថ្វាយនំកុម្មាសទាំងនោះ ឱ! ព្រះពុទ្ធមានមហាគុណអស្ចារ្យមែនហ្ន៎!" ។ ព្រះសាស្តាស្តេចយាងមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាអំពីរឿងអ្វី?" កាលភិក្ខុទាំងឡាយក្រាបទូលថា "ដោយរឿងឈ្មោះនេះ" ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនជាអស្ចារ្យទេ ដែលព្រះនាងមល្លិកាថ្វាយនំកុម្មាស ៣ ដុំដល់ព្រះសព្វញ្ញុពុទ្ធមួយអង្គហើយបានភាពជាអគ្គមហេសីរបស់ព្រះបាទកោសលនោះ ព្រោះហេតុអ្វី ? ព្រោះភាពជាអ្នកមានគុណធំរបស់

ព្រះពុទ្ធ (ព្រះពុទ្ធមានគុណធំ) ។ ចំណែកឯបោរាណក បណ្ឌិតទាំងឡាយថ្វាយនំកុម្មាសដែលមិនប្រៃ មិនមានប្រេង មិនមានស្ករអំពៅ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ដោយផលនៃទាននោះ ក្នុងអត្តភាពទី ២ ក៏បានដល់នូវសិរីរាជសម្បត្តិ ក្នុងដែនកាសី ដែលមានទំហំ ៣០០ យោជន៍" ដូច្នេះហើយ ព្រះសម្ពុទ្ធក៏នាំយកអតីតនិទាន **រឿងកុម្មាសបិណ្ឌិ** មកសម្ដែងជាធម្មទាន ។

សត្វទាំងឡាយ ដែលមានសទ្ធាដល់គុណព្រះរតនៈត្រៃ ចូរបើកសោតបសាទប្រកបព្រមដោយការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃបញ្ញាសូមស្ដាប់ដោយគោរពចុះ។

# អតីតនិទាន

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយ-រាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកក្រីក្រមួយ កាលចម្រើនវ័យធំហើយក៏ចូលធ្វើការស៊ីឈ្នួលឲ្យសេដ្ឋីម្នាក់ ដើម្បីចិញ្ចឹមជីវិត ។

ថ្ងៃមួយ ព្រះពោធិសត្វកាន់នំកុម្មាស ៤ ដុំមកអំពីផ្សារដោយគិតថា "នំកុម្មាសទាំងនេះនឹងជាអាហារព្រឹករបស់យើង" ពេលលោកកំពុងទៅធ្វើការ បានឃើញព្រះបច្ចេកពុទ្ធ ៤ អង្គ កំពុងចូលមក មានមុខឆ្ពោះកាន់នគរពារាណសីដើម្បីបិណ្ឌបាត ។

ព្រះពោធិសត្វ(មាណព)គិតថា

"លោកម្ចាស់ទាំងនេះ ទៅកាន់ក្រុងពារាណសី សំដៅទៅរកភិក្ខា ចំណែកយើងមាននំកុម្មាស ៤ ដុំ យើងគប្បីប្រគេននំទាំងនេះដល់លោកម្ចាស់" គិតហើយ ក៏ម្នីម្នាចូលទៅជិត ថ្វាយបង្គំព្រះបច្ចេកពុទ្ធ រួចពោលថា

"បពិត្រលោកម្ចាស់ ខ្ញុំករុណាមាននំកុម្មាស ៤ ដុំ ក្នុងដៃ ខ្ញុំសូមប្រគេននំទាំងនេះដល់លោកម្ចាស់ សូមលោកម្ចាស់មេត្តាទទួលនំទាំងនេះចុះ បុណ្យនឹងជារបស់ខ្ញុំ នឹងបានជាប្រយោជន៍ និងសេចក្ដីសុខអស់កាលដ៏យូរ" ។ ដោយព្រះពោធិសាត្វបានដឹងការទទួលនិមន្តរបស់ព្រះបច្ចេកពុទ្ធហើយ លោកក៏បានពូនខ្សាច់ និងរៀបចំអាសនៈ បាំងពិតានខាងលើ និមន្តព្រះបច្ចេកពុទ្ធឲ្យគង់តាមលំដាប់ នាំផ្ទាំងដែលមានទឹកពេញមកស្រោចនូវទក្ខិណោទក តម្កល់នំកុម្មាស ៤ ដុំទុក រួចថ្វាយបង្គំ ហើយពោលថា

"ភន្តេ ឯតេសំ និស្សន្ទេន ទលិទ្ទគេហេ និព្វត្តិ នាម មា ហោតុ, សព្វញ្ញុតញ្ញាណប្បដិវេធស្ស បច្ចយោ ហោតុ បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយផលនៃការថ្វាយនំកុម្មាសទាំងនេះ ដែលឈ្មោះថា ការកើតក្នុងផ្ទះក្រីក្រ សូមកុំឲ្យមានឡើយ, និងសូមជាបច្ច័យ

នៃការចាក់ផ្ទុះ បានសម្រេច ត្រាស់ដឹងនូវសព្វញ្ញុត-ញ្ញាណ" ។ ព្រះបច្ចេកពុទ្ធទាំងឡាយ បន្ទាប់ពីបានឆាន់រួចហើយ លោកធ្វើអនុមោទនា រួចហោះទៅកាន់ញកភ្នំនន្ទមូលក៍វិញ ។

ព្រះពោធិសត្វផ្គងអញ្ជលី កាន់យកបីតិ ដែលមានដំណើរព្រះបច្ចេកពុទ្ធជាអារម្មណ៍ ពេលព្រះបច្ចេកពុទ្ធទាំងនោះកន្លងផុតចក្ខុវិស័យហើយ លោកក៏ទៅធ្វើការនឹករលឹកនូវទានរហូតដល់អស់អាយុ។ លុះដល់កាលធ្វើកិរិយាហើយ, ដោយផលនៃទាននោះ បានកើតក្នុងផ្ទៃព្រះអគ្គមហេសី របស់ព្រះបាទពារាណសី (កាលប្រសូតហើយ) ញាតិទាំងឡាយដាក់ព្រះនាមឲ្យថា **ព្រហ្មទ-ត្តកុមារ** ។ ព្រះពោធិសត្វនោះ ចាប់ពីពេលដែលចេះដើរដោយព្រះបាទមក ទ្រង់ឃើញកិរិយាអាការៈរបស់ខ្លួនក្នុងជាតិមុនយ៉ាងប្រាកដជាក់ច្បាស់ ដោយ**ជាតិស្សរញាណ** (ញាណជាគ្រឿងរលឹកជាតិ) ដូចឃើញមុខក្នុង

កញ្ចក់ដែលថា ថា យើងជាអ្នកធ្វើនូវការស៊ីឈ្នួលក្នុង នគរនេះឯង កាលទៅធ្វើការ បានថ្វាយនំកុម្មាស ៤ដុំ ប្រគេនចំពោះព្រះបច្ចេកពុទ្ធ ដោយផលនៃទាននោះ ទើបបានកើតក្នុងទីនេះ ។ ព្រះពោធិសត្វកាលធំពេញ-វ័យហើយ បានទៅកាន់នគរតក្កសិលា សិក្សារៀនសូត្រ សិល្បសាស្ត្រទាំងពួង ហើយត្រឡប់មក សម្តែងសិល្បៈ ដែលខ្លួនបានសិក្សាថ្វាយព្រះបិតា ព្រះរាជបិតាមានចិត្ត ត្រេកអរ បានតែងតាំងព្រះរាជបុត្រជាឧបរាជ ។ លុះដល់ ខាងក្រោយមក កាលបិតាកន្លងផុតទៅ ព្រះពោធិសត្វក៏ បានតាំងនៅក្នុងរាជសម្បត្តិ ។ លំដាប់នោះ អាមាត្យ ទាំងឡាយនាំព្រះរាជធីតារបស់ព្រះបាទកោសលដែល មានរូបដ៏ឧត្តម មកអភិសេកធ្វើជាអគ្គមហេសីរបស់ព្រះ អង្គ។ ក្នុងថ្ងៃ**ឆត្តមង្គល**របស់ព្រះអង្គ មនុស្សទាំងឡាយ នាំគ្នាតាក់តែងនគរទាំងមូលឲ្យដូចជាទេវនគរ ។

*ព្រះពោធិសត្វធ្វើប្រទក្សិណនគរហើយ ស្ដេច-ឡើងកាន់**អលង្កតប្រាសាទ** ទ្រង់ឡើងប្រថាប់លើបល្ល័ង្ក ដែលមាន**សមុស្សិតស្វេតច្ឆត្រ**បាំងទុក នៅកណ្ដាល**មហាតលដ្ឋាន** ទ្រង់សម្លឹងមើលសិរីសម្បត្តិដែលជាទីត្រេកអរនៃចិត្តដ៏ក្រៃលែង គឺមានពលនិករទាំងឡាយដែលនាំគ្នាមកគាល់ មួយចំណែកជាពួកអាមាត្យ, មួយចំណែកជាគហបតី មានព្រាហ្មណ៍គហបតីជាដើមដែលជាអ្នកមានសម្បត្តិផ្សេងៗ និងមានភាពរុងរឿងដោយសិរីដ៏វិសាល។ មួយចំណែកមានជាប្រជាជនអ្នកក្រុងដែលមានដៃកាន់គ្រឿងបណ្ណាការផ្សេងៗ, មួយចំណែកជាពួកស្រីរបាំដែលមានចំនួន ១៦០០០ នាក់ ហាក់បីដូចជាពួកស្រីទេពអប្សរដែលប្រដាប់តាក់តែងហើយ។*

*ពេលនោះព្រះរាជា ក៏រលឹកបុព្វកម្មរបស់ខ្លួន និងរលឹកគុណព្រះបច្ចេកពុទ្ធថា "សិរីសម្បត្តិសូម្បីទាំងអស់នេះ គឺ*

សុវណ្ណបិណ្ឌិកៈ កម្រងផ្កាមាស ស្វេតច្ឆត្រ ហត្ថិពាហនៈ អស្សពាហនៈ រថពាហនៈជាច្រើនពាន់ ឃ្លាំងដែលពេញដោយកែវមណី កែវមុក្តាជាដើម មហាប្រឹថពីដែលពេញដោយធញ្ញជាតិផ្សេងៗ នារីទាំងឡាយដែលមានសភាពដូចជាទេពអប្សរ សិរីសម្បត្តិរបស់យើងទាំងអស់នេះ មិនមែនបានមកអំពីសម្នាក់បុគ្គលដទៃ គឺបានមកអំពីការថ្វាយនំកុម្មាស ៤ ដុំ ដល់ព្រះបច្ចេកពុទ្ធ ៤ អង្គ, យើងអាស្រ័យព្រះបច្ចេកពុទ្ធទាំងនេះ ទើបបានសម្បត្តិទាំងនេះ″ ។ ដូច្នេះទ្រង់ក៏ធ្វើកម្មរបស់ខ្លួនឲ្យប្រាកដ ។ កាលទ្រង់កំពុងរលឹកនូវបុព្វកម្មនោះឯង បីតិក៏ពេញប្រៀបទូទាំងសរីរកាយតាំងពីបាទដើងរហូតដល់ចុងនៃសក់ ។ ព្រះពោធិសត្វមានព្រះទ័យសើមដោយបីតិ កាលនឹងច្រៀងនូវ**ឧទានគីតៈ** (ចម្រៀងជាការបន្លឺឧទានវាចា) ក្នុងកណ្តាលមហាជន ទើបត្រាស់ ២ គាថាថា

១.    ន កិរត្ថិ អនោមទស្សិសុ

ចារិចរិយា ពុទ្ធេសុ អប្បិកា
សុក្ខាយ អលោណិកាយ ច
បស្ស ផលំ កុម្មាសបិណ្ឌិយា ។

បានឮថា ការបម្រើព្រះបច្ចេកពុទ្ធទាំងឡាយ ដែលលោកមានពោធិញ្ញាណ មិនថោកថយ មិនមែនមានផលានិសង្សតិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសដែលសោះកក្រោះ ឥតរសប្រៃ (ធម្មតាទោះសម្លក្តីពេលយើងចង់បានឱជារសយើងក៏បន្ថែមអំបិលមួយចឹបដើម្បីបានរសជាតិ ចំណែកនំកុម្មាសដែលលោកពោលថាឥតរសប្រៃគឺទំនង់គ្មានរសជាតិឆ្ងុយឆ្ងាញ់គួរឱ្យចង់បរិភោគឡើយ)។

២. ហត្ថិគវាស្សា ចិមេ ពហូ
ធនធញ្ញំ បឋវី ច កេវលា
នារិយោ ចិមា អច្ឆរូបមា
បស្ស ផលំ កុម្មាសបិណ្ឌិយា ។

ដំរី គោ និងសេះ ដ៏ច្រើនទាំងនេះផង ទ្រព្យ ស្រូវ និងផែនដីទាំងអស់ផង នាងនារីទាំងឡាយដែលប្រៀបដូចជាស្ត្រីអប្សរទាំងនេះផង សុទ្ធតែជារបស់ខ្ញុំ អ្នកចូរមើលនូវផលនៃដុំនំកុម្មាស ។

## សេចក្តីអធិប្បាយ

ទក្ខិណាទានដែលទាយកកំណត់គុណរបស់សមណព្រាហ្មណ៍ទាំងឡាយ ញុំាំងចិត្តឲ្យជ្រះថ្លា ញុំាំងចេតនាទាំង ៣ របស់អ្នកប្រាថ្នាការកើតផល ឲ្យផូរផង់ហើយទើបថ្វាយ ឈ្មោះថា មានផលតិច រមែងមិនមាន មានតែនឹងឲ្យមហាសម្បត្តិ ក្នុងភពដែលកើតហើយប៉ុណ្ណោះ ព្រោះហេតុនោះ ក្នុងទីនេះ ទើបមានពាក្យដែលលោកពោលជាសាធកៈថា

នត្ថិ ចិត្តេ បសន្នម្ហិ, អប្បិកា នាម ទក្ខិណា;
តថាគតេ វា សម្ពុទ្ធេ, អថ វា តស្ស សាវកេ។

កាលបើ ចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវ័ករបស់ព្រះតថាគតហើយ ទក្ខិណាទាន ឈ្មោះថា មានផលតិច មិនមែនឡើយ[១] ។

តិដ្ឋន្តេ និព្ពុតេ ចាបិ, សមេ ចិត្តេ សមំ ផលំ;
ចេតោបណិធិហេតុ ហិ, សត្តា គច្ឆន្តិ សុគ្គតិំ។

កាលព្រះតថាគតឋិតនៅក្ដី បរិនិព្វានទៅក្ដី បើ តាំងចិត្តស្មើ ផលក៏ស្មើ ព្បិតថា សត្វទាំងឡាយ មានការ តម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន[១] ។

ដើម្បីសម្ដែងសេចក្ដីនោះ គប្បីនាំរឿងក្នុង**វិមានវត្ថុ** មកជាសាធក: មានជាដើមយ៉ាងនេះថា

ទីពេទធំ អហាមធាសិំ,
ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស។

---

[១]. ខុទ្ទក. វិមានវត្ថុ បីតវិមាន បិ. ៥៥ ទំ. ១០០-១០១ ។

*ខ្ញុំបានឲ្យនូវបាយដែលលាយដោយទឹកដោះស្រស់ ដល់ភិក្ខុដែលត្រាច់ទៅដើម្បីបិណ្ឌបាត[១] ។*

តស្សា មេ បស្ស វិមានំ,
អច្ឆរា កាមវណ្ណិនីហមស្មិ។

*សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ។*

អច្ឆរាសហស្សស្សាហំ,
បវរា បស្ស បុញ្ញានំ វិបាកំ;
តេន មេតាទិសោ វណ្ណោ,
តេន មេ ឥធ មិជ្ឈតិ។

*ខ្ញុំជាស្រីប្រសើរ ជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោករមិលមើល នូវផលនៃបុណ្យទាំងឡាយ ព្រោះ*

---

*១ . វិមានវត្ថុ បិ. ៥៥ ទំ. ៦៨ ។*

ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង[2] ។

ឧប្បជ្ជន្តិ ច មេ ភោគា,
យេ កេចិ មនសោ បិយា;
តេនម្ហិ ឯវំ ជលិតានុភាវា,
វណ្ណោ ច មេ សព្វទិសា បភាសតិ។

ភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង ខ្ញុំមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

បានឮមកថា ព្រះពោធិសត្វទាំងឡាយ និងព្រះសព្វញ្ញុពុទ្ធទាំងឡាយតែងដឹងនូវផលរបស់ទាន ។ ដោយហេតុនោះឯង ព្រះសាស្ដាកាលសម្ដែងសុត្តន្តៈក្នុងឥតិវុត្តកៈ បានត្រាស់ថា

[2] ២. វិមានវត្ថុ បិ. ៥៥ ទំ. ៦៨ ។

ឯវញ្ចេ ភិក្ខវេ សត្តា ជានេយ្យុំ ទានសំវិភាគស្ស វិបាកំ, យថាហំ ជានាមិ, ន អទត្វា ភុញ្ជេយ្យុំ, ន ច នេសំ មច្ឆេរមលំ ចិត្តំ បរិយាទាយ តិដ្ឋេយ្យ។ យោបិ នេសំ អស្ស ចរិមោ អាលោបោ ចរិមំ កពឡំ, តតោបិ ន អសំវិភជិត្វា ភុញ្ជេយ្យុំ, សចេ នេសំ បដិគ្គាហកា អស្សុ។ យស្មា ច ខោ ភិក្ខវេ សត្តា ន ឯវំ ជានន្តិ ទានសំវិភាគស្ស វិបាកំ, យថាហំ ជានាមិ, តស្មា អទត្វា ភុញ្ជន្តិ, មច្ឆេរមលញ្ច នេសំ ចិត្តំ បរិយាទាយ តិដ្ឋតិ។

*ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ មួយទៀតមន្ទិល គឺសេចក្តីកំណាញ់ របស់សត្វទាំងនោះ ក៏មិនគ្របសង្កត់ចិត្តបានឡើយ ។ ទោះបីពំនូកបាយជាដំបូង ឬដុំបាយជាដំបូងឯណារបស់សត្វទាំងឡាយនោះ សត្វទាំងឡាយមិនបានរំលែកអំពីពំនូតបាយនោះ ក៏មិនបរិភោគឡើយ បើសត្វទាំងនោះមានបដិគ្គាហកបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ*

តថាគតដឹងផលនៃការឲ្យ និងការចែករំលែកយ៉ាងណា សត្វទាំងឡាយ មិនដឹងយ៉ាងនោះទេ ព្រោះហេតុណា ហេតុនោះ សត្វទាំងឡាយមិនបានឲ្យទានហើយ ទើបហ៊ានបរិភោគ មួយទៀត មន្ទិលសេចក្ដីកំណាញ់ ក៏តែងគ្របសង្កត់ចិត្តសត្វទាំងឡាយនោះ[៣]។

ព្រះពោធិសត្វ ទ្រង់មានបីតិបាមោជ្ជៈកើតឡើងក្នុងថ្ងៃ**ឆត្តមង្គល**របស់ខ្លួន ទើបទ្រង់ច្រៀងនូវ**ឧទាន-គីតៈ** ២ គាថានេះ ។ ចាប់ពីពេលនោះមក ស្រ្តីរបាំទាំងឡាយរបស់ព្រះពោធិសត្វ ក៏នាំគ្នាច្រៀងនូវចម្រៀងនោះដោយគិតថា "នេះជាចម្រៀងជាទីពេញព្រះទ័យរបស់ព្រះរាជា" សូម្បីស្រ្តីជា **នាដកគន្ធព្វ**ដ៏សេសក្ដី ជនដែលនៅក្នុងព្រះរាជវាំងក្ដី អ្នករស់នៅក្នុងរាជធានីក្ដី អ្នករស់នៅខាងក្រៅនគរក្ដី អ្នកនៅក្នុងរោងសុរាក្ដី តែងនាំគ្នាច្រៀងនូវចម្រៀងនោះដោយគិតថា "នេះជាចម្រៀងជាទីពេញព្រះទ័យនៃព្រះរាជារបស់ពួកយើង" ។

---

[៣] . ខុទ្ទក. ឥតិវុត្តក ទានសូត្រ បិ. ៥៣ ទំ. ២៥-២៦ ។

ពេលវេលាក៏បានកន្លងយូរល្មមទៅហើយនោះ ព្រះអគ្គមហេសីមានសេចក្តីប្រាថ្នាចង់ដឹងអត្ថន័យរបស់ចម្រៀងនោះ តែមិនអាចទូលសួរព្រះមហាសត្វ ។ នៅថ្ងៃមួយ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងគុណសេចក្តីល្អមួយរបស់ព្រះនាង ទើបត្រាស់ថា "ម្នាលនាងដ៏ចម្រើន យើងនឹងឲ្យពរដល់នាង នាងចូរទទួលពរចុះ" ។ ព្រះនាងទូលថា "ប្រពៃណាស់ បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់សូមទទួល" ។ ព្រះពោធិសត្វត្រាស់ថា "ក្នុងបណ្តាដំរីនិងសេះជាដើម យើងនឹងឲ្យអ្វីដល់នាង ?" ព្រះនាងទេវីទូលថា "បពិត្រព្រះសម្មតិទេព មិនមានរបស់អ្វីដែលខ្ញុំម្ចាស់មិនមាន ដោយអាស្រ័យព្រះអង្គឡើយ ខ្ញុំម្ចាស់មិនមានសេចក្តីត្រូវការដោយវត្ថុទាំងនោះ ប្រសិនបើព្រះអង្គមានសេចក្តីប្រាថ្នាប្រទានពរ សូមត្រាស់ប្រាប់អត្ថន័យនៃចម្រៀង ដែលព្រះអង្គនិពន្ធនេះ ដល់ខ្ញុំម្ចាស់ចុះ" ។ ព្រះរាជាត្រាស់ថា "ម្នាលនាង នាងនឹងមានប្រយោជន៍អ្វីដោយពរនេះ នាងចូរទទួលពរដទៃចុះ" ។ ព្រះអគ្គមហេសីទូលថា "បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់

មិនមានសេចក្ដីត្រូវការពរដទៃទេ សូមទទួលតែពរនេះប៉ុណ្ណោះ" ។

ព្រះរាជាត្រាស់ថា "ល្អហើយនាង យើងនឹងប្រាប់ ប៉ុន្តែយើងមិនប្រាប់ដល់នាងតែម្នាក់ក្នុងទីស្ងាត់ទេ យើងឲ្យរាជបុរសត្រាច់វាយស្គរប្រកាសក្នុងនគរពារាណសីដែលទំហំ ១២ យោជន៍ ឲ្យគេសាង**រតនមណ្ឌល**ត្រង់រាជទ្វារ ឲ្យគេរៀបចំ**រតនបល្ល័ង្ក** ឲ្យពួកអាមាត្យ ពួកព្រាហ្មណ៍ជាដើមផង ឲ្យពួកអ្នកនគរផង ឲ្យពួកស្រី ១៦០០០ ផងអង្គុយចោមរោមជាបរិវារ ហើយយើងនឹងអង្គុយលើរតនបល្ល័ង្ក នៅកណ្ដាលបរិស័ទទាំងនោះ ហើយនឹងសម្ដែងប្រាប់" ។ ព្រះទេវីទទួលថា "សាធុ ព្រះសម្មតិទេព" ។

ព្រះរាជាឲ្យធ្វើយ៉ាងនោះ ទ្រង់មានពួកមហាជនចោមរោមហាក់ដូចជាសក្កទេវរាជដែលមានពួក ទេវតាចោមរោម ទ្រង់ប្រដាប់លើរតនបល្ល័ង្ក ។ ចំណែកព្រះទេវីប្រដាប់តាក់តែង ដោយគ្រឿងអលង្ការទាំងពួង ទ្រង់រៀបចំតាំងមាស ព្រះនាងសម្លឹងមើលដោយចុងភ្នែកម្ខាងហើយគង់ក្នុងទីបែបនោះ រួចពោលថា

"បពិត្រព្រះសម្មទិទេព សូមព្រះអង្គត្រាស់ប្រាប់អត្ថន័យចម្រៀងមង្គល ដែលព្រះអង្គរីករាយព្រះទ័យ ហើយតែងតែស្រែកច្រៀងនោះ ដល់ខ្ញុំម្ចាស់ ឲ្យបានជាក់ច្បាស់ ឲ្យដូចជាធ្វើព្រះចន្ទឲ្យពេញវង់ក្នុងកណ្តាលអាកាសផងចុះ" ដូច្នេះហើយ ព្រះនាងក៏ពោលគាថាទី ៣ ថា

៣. អភិក្ខណំ រាជកុញ្ជរ
គាថា ភាសសិ កោសលាធិប
បុច្ឆាមិ តំ រដ្ឋវឌ្ឍន
ពាឡ្ហំ បីតិមនោ បភាសសិ ។

បពិត្រព្រះរាជកុញ្ជរ មានព្រះអធ្យាស្រ័យជាកុសល ទ្រង់ញុំាងដែនឲ្យចម្រើន ព្រះអង្គត្រាស់គាថាទាំងឡាយរឿយៗ ខ្ញុំម្ចាស់សូមក្រាបបង្គំទូលសួរទ្រង់ ព្រះអង្គមានព្រះទ័យ ប្រកបដោយបីតិក្រៃពេក ហើយទ្រង់ត្រាស់ ( គាថាទាំងនុ៎ះ ) ។

*លំដាប់នោះ ព្រះមហាសត្វកាលនឹងធ្វើអត្ថន័យរបស់គាថាទាំងឡាយនោះឲ្យជាក់ច្បាស់ ទើបត្រាស់ ២ គាថា ថា:*

៤. ឥមស្មិំយេវ នគរេ
កុលេ អញ្ញតរេ អហុំ
បរកម្មករោ អាសិំ
ភតកោ សីលសំវុតោ ។

៥. កម្មាយ និក្ខមន្តោហំ
ចតុរោ សមណេទ្ទសំ
អាចារសីលសម្បន្នេ
សីតភូតេ អនាសវេ ។

*យើងបានកើតក្នុងត្រកូលមួយ ក្នុងក្រុងនេះដែរ ជាអ្នកស៊ីឈ្នួលធ្វើការងាររបស់បុគ្គលដទៃ ជាអ្នកសង្រួមក្នុងសីលយើងចេញទៅធ្វើការ បានជួបនឹងសមណ: ៤ អង្គ លោក បរិបូណ៌ដោយអាចារ: និងសីល មានសេចក្តីត្រជាក់ទាំងឥតមានអាសវ:ឡើយ ។*

៦. តេសុ ចិត្តំ បសាទេត្វា
និសីទិត្វា បណ្ណសន្ថតេ
អទំ ពុទ្ធាន កុម្មាសំ
បសន្នោ សេហិ បាណិភិ ។

យើងបានញុំាំងចិត្តឲ្យជ្រះថ្លា ចំពោះសមណៈទាំងនោះ បាននិមន្តលោកឲ្យគង់លើកម្រាលស្លឹកឈើ លុះយើងមានចិត្តជ្រះថ្លាហើយ បានប្រគេននំកុម្មាសៈ ដល់ព្រះបច្ចេកពុទ្ធដោយដៃខ្លួនឯង ។

៧. តស្ស កម្មស្ស កុសលស្ស
ឥទំ មេ ឯទិសំ ផលំ
អនុភោមិ ឥទំ រជ្ជំ
ផីតំ ធរណិមុត្តមំ ។

ឯផលរបស់យើងប្រាកដ ដូច្នេះនេះ ជាផលរបស់កម្ម ជាកុសលនោះ យើងសោយរាជ្យដ៏ស្តុកស្តម្ភ ប្រសើរលើធរណីនេះ ។

កាលព្រះមហាសត្វប្រាប់ផលកម្មដ៏ពិស្ដារ របស់ខ្លួនយ៉ាងនេះហើយ ព្រះទេវីស្ដាប់ហើយ ព្រះនាងមានព្រះទ័យជ្រះថ្លា ពោលថា "បពិត្រមហារាជ ប្រសិនបើព្រះអង្គជ្រាបផលទាន ដោយប្រចក្សយ៉ាងនេះហើយ តាំងតែឥឡូវនេះទៅ ព្រះអង្គបានជុំកត្តហើយ ត្រូវប្រគេនសមណព្រាហ្មណ៍ ដែលប្រកប ដោយធម៌ (មុនហើយ) សឹមព្រះអង្គសោយ (ជាខាងក្រោយ)" ដូច្នេះកាលនឹងធ្វើការសរសើរព្រះពោធិសត្វ ទើបពោលថា

៨. ទទំ ភុញ្ជ មា ច បមាទោ
ចក្កំ វត្តយ កោសលាធិប
មា រាជ អធម្មិកោ អហុ
ធម្មំ បាលយ កោសលាធិប ។

បពិត្រព្រះអង្គមានព្រះអធ្យាស្រ័យ ជាកុសល សូមព្រះអង្គព្រះរាជទាន ហើយសូមទ្រង់សោយ សូមព្រះអង្គ ទ្រង់កុំប្រមាទ ( ក្នុងបុណ្យទាំងឡាយ ) សូមព្រះ

*អង្គញុំាំងចក្កធម៌ ឲ្យប្រព្រឹត្តទៅ បពិត្រព្រះរាជា មានព្រះអធ្យាស្រ័យ ជាកុសល ព្រះអង្គកុំជាអ្នកមិនប្រកប ដោយធម៌ សូមទ្រង់រក្សានូវអនុធម៌ ។*

## សេចក្ដីអធិប្បាយ

*បពិត្រមហារាជ ដែលជាអ្នកមានអធ្យាស្រ័យក្នុងកុសល សូមព្រះអង្គញុំាំងធម្មចក្រ ដែលមាន ៤ ប្រការ មាន**បតិរូបទេសវាស** (ការរស់នៅក្នុងប្រទេសដ៏សមគួរ) ជាដើម ឲ្យប្រព្រឹត្តទៅ ។ ពិតមែនហើយ រថប្រក្រតីតែងទៅដោយចក្រ (គឺកង់) ទាំង ២, ប៉ុន្តែកាយនេះ រមែងទៅកាន់ទេវលោក (បាន) ដោយចក្រ (គឺកង់) ទាំង ៤ នេះ,*

ហេតុនោះ ចក្រទាំង ៤ នោះ ដល់ការរាប់ថាជា **ធម្មចក្រ** [៤] ។ ព្រះអង្គចូរញ៉ាំងចក្រនោះឲ្យប្រព្រឹត្តទៅ ។

មនុស្សដទៃដល់ការលម្មៀង ព្រោះសេចក្តីស្រឡាញ់ រមែងបៀតបៀនសត្វលោក រឹបអូសយកទ្រព្យសម្បត្តិ មានឧបមាដូចជាម៉ាស៊ីនគាបអំពៅដែលគេបានគាបយករសផ្អែម និងទឹកអស់សល់តែកាកបុណ្ណោះ ជាអ្នកមិនប្រកបដោយធម៌ យ៉ាងណា សូមព្រះអង្គកុំជាអ្នកមិនប្រកបដោយធម៌យ៉ាងនោះឡើយ ។

---

[៤]. **ធម្មចក្ក ៤** គឺ ៖

១. **បដិរូបទេសវាសោ** ការនៅក្នុងប្រទេសដ៏សមគួរ

២. **សប្បុរិសាវស្សយោ** ការចូលទៅសេពគប់នឹងពួកសប្បុរស

៣. **អត្តសម្មាបណិធិ** ការតម្កល់ទុកខ្លួនដោយល្អ

៤. **បុព្វេ កាតបុញ្ញតា** បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន ។

(អង្គុត្តរនិកាយ ចតុក្កនិបាត ចក្កសូត្រ បិ. ៤២ ទំ. ៧៩)

*សូមព្រះអង្គគ្រប់គ្រង គឺរក្សា ព្រមដោយធម៌ហើយ ទ្រង់កុំលះបង់នូវ **ទសពិធរាជធម៌**នេះ គឺ ៖*

ទានំ សីលំ បរិច្ចាគំ, អជ្ជវំ មទ្ទវំ តបំ;
អក្កោធំ អវិហឹសញ្ច, ខន្តិញ្ច អវិរោធនំ។

*ការឱ្យ ១ ការរក្សាសីល ១ ការបរិច្ចាគ ១ ភាពជាអ្នកមានចិត្តត្រង់ ១ ភាពនៃចិត្តទន់ភ្លន់ ១ តបៈ គឺអត់ធ្មត់រក្សានូវឧបោសថសីល ១ ការមិនក្រោធខឹង ១ ការមិនបៀតបៀន ១ ខន្តីអត់ទ្រាំ ១ កិរិយាមិនភ្ញាត់ឃ្លាតចាកកុសលធម៌ ១[៥] ។*

*ព្រះមហាសត្វកាលនឹងទទួលពាក្យរបស់ព្រះនាងទើបត្រាស់ថា*

៩. សោហំ តទេវ បុនប្បុនំ
វជុមំ អាចរិស្សាមិ សោភនេ

*[៥].ខុទ្ទក. ជាតក. អសីតិនិបាត មហាហំសជាតក បិ. ៦១ ទំ. ១២៨ ។*

អរិយាចរិតំ សុកោសលេ

អរហន្តោ មេ មនាបាវ បស្សិតុំ ។

ម្នាលនាងមានពោមល្អ យើងនោះនឹងដើរតាមតម្រាយដែលព្រះអរិយៈធ្លាប់ប្រព្រឹត្តរឿយៗ មកនោះឯងម្នាលនាងដ៏ល្អជាធីតារបស់ព្រះបាទកោសល ការបានជួបនឹងព្រះអរហន្តទាំងឡាយ ជាទីគាប់ចិត្តរបស់យើងពន់ពេក ។

ក៏ឯព្រះរាជាត្រាត្រាស់ពាក្យនេះហើយ ទ្រង់សម្លឹងមើលសម្បត្តិ របស់ព្រះទេវី ក៏ត្រាស់ថា ម្នាលនាងដ៏ចម្រើន យើងប្រាប់កុសលកម្ម របស់ខ្លួនក្នុងជាតិមុនយ៉ាងពិស្តារដល់នាងហើយ, ចំណែកក្នុងស្ត្រីទាំងឡាយនេះ មិនមានស្ត្រីសូម្បីតែម្នាក់ដែលស្មើនឹងនាងដោយរូបឬដោយដំណើរយាងយាសកែក្រាយ នាងបានធ្វើកម្មអ្វីទើបបានទទួលសម្បត្តិនេះ ដូច្នេះកាលនឹងសួរ ទើបទ្រង់ត្រាស់គាថាបន្តទៀតថា

១០. ទេវីវិយ អច្ឆរូបមា
មជ្ឈេ នារិគណស្ស សោភសិ
កឹ កម្មមកាសិ ភទ្ទកំ
កេនាសិ វណ្ណវតី សុកោសលេ ។

ម្នាលនាងសុកោសលធីតា នាងប្រៀបដូចជាស្រ្តីទេពអប្សរ ជាទេវធីតា ( របស់សក្កទេវរាជ ) ឆើតឆាយក្នុងកណ្តាលនៃពួកនាងនារី នាងបានធ្វើនូវកម្មដ៏ចម្រើនដូចម្តេច នាងមានសម្បុរល្អ ដោយហេតុអ្វី ។

គាថានេះមានសេចក្តីថា ម្នាលនាងសុធីតារបស់ព្រះបាទកោសលដ៏ចម្រើន នាងមានឧបមាដូចទេពអប្សរ ដោយរូបសម្បត្តិ ស្រស់ស្អាតដ៏លើស ក្នុងកណ្តាលពួកនារី ដូចជាទេវធីតាណាមួយរបស់សក្កទេវរាជ ក្នុង**តិទសបុរី**ឋានត្រៃត្រិង្ស ក្នុងកាលមុន នាងបានធ្វើកល្យាណកម្មអ្វី ព្រោះហេតុអ្វី ទើបនាងមានសម្បុរដ៏រុងរឿងគ្មានកន្លែងណាមួយដែលទាស់ត្លង់ឡើយ ។

លំដាប់នោះ ព្រះនាងទេវីកាលនឹងប្រាប់កល្យាណកម្មក្នុងជាតិមុនដល់ព្រះរាជា ទើបត្រាស់គាថាទាំង ២ ដ៏សេសថា

១១. អម្ពដ្ឋកុលស្ស ខត្តិយ
ទាស្យាហំ បរបេសិយា អហុំ
សញ្ញតា ច ធម្មជីវិនី
សីលវតី ច អបាបទស្សនា ។

បពិត្រក្សត្រិយ៍ ខ្ញុំម្ចាស់ជាទាសីបម្រើអ្នកដទៃរបស់ត្រកូលអម្ពដ្ឋៈ ជាស្ត្រីសង្រួម ចិញ្ចឹមជីវិតដោយធម៌ មានសីលធម៌មានការឃើញមិនអាក្រក់ ។

១២. ឧទ្ធដភត្តំ អហំ តទា
ចរមានស្ស អទាសិ ភិក្ខុនោ
វិត្តា សុមនា សយំ អហំ
តស្ស កម្មស្ស ផលំ មមេទិសំ ។

កាលនោះ ខ្ញុំជាស្ត្រីមានចិត្តត្រេកអរីករាយ ខ្លួនឯង មិនមានបុគ្គលជាគម្រប់ពីរឡើយ បានប្រគេនភត្ត

ដែលគេដួស ( ទុកបម្រុងខ្ញុំ ) ដល់ភិក្ខុ ( ព្រះបច្ចេកពុទ្ធ ) ដែលត្រាច់ទៅ ( ដើម្បីបិណ្ឌបាត ) ផលប្រាកដដូច្នេះនេះ គឺជាផលនៃបុញ្ញកម្មនោះ ។

**សេចក្តីអធិប្បាយ**

បានឮមកថា សូម្បីព្រះនាងទេវី ក៏ជាអ្នកអាចរលឹកជាតិបានដូចគ្នា, ព្រោះហេតុនោះ ព្រះនាងទើបទូលព្រះរាជា ដោយកំណត់ដឹងដោយ ជាតិស្សរញ្ញាណរបស់ខ្លួន ។

ព្រះនាងពោលថា បពិត្រមហារាជ ក្នុងកាលមុនខ្ញុំម្ចាស់ជាទាសីរបស់ត្រកូលកុដុម្ពិយៈ (ត្រកូលអ្នកស្រែចម្ការ)  មួយក្នុងក្រុងសាវត្ថី កាន់យកភត្តដែលជាចំណែកដែលខ្លួនបានចេញទៅ បន្ទាប់មកក៏បានឃើញព្រះបច្ចេកពុទ្ធមួយព្រះអង្គដែលកំពុងត្រាច់បិណ្ឌបាត ខ្ញុំម្ចាស់លះតណ្ហារបស់ខ្លួន ជាអ្នកដល់ព្រមដោយគុណមានការសង្រួមជាដើម ជឿកម្មផល បានប្រគេនភត្តនោះ

*ដល់ព្រះបច្ចេកពុទ្ធអង្គនោះ, ខ្ញុំម្ចាស់នោះ ឋិតនៅដរាបដល់អស់អាយុហើយ ធ្វើកាលកិរិយា បានកើតក្នុងផ្ទៃព្រះអគ្គមហេសីរបស់ព្រះបាទកោសលក្នុងក្រុងសាវត្ថីនោះ ឥឡូវនេះ ខ្ញុំម្ចាស់កំពុងបម្រើព្រះបាទារបស់ព្រះអង្គ បានសោយសម្បត្តិបែបនេះ, ផលកម្មរបស់ខ្ញុំម្ចាស់នោះ ជាយ៉ាងនេះឯង ។ ក្នុងរឿងនោះ ដើម្បីសម្តែងភាវៈនៃទានដែលឲ្យដល់អ្នកដល់ព្រមដោយគុណ ជាទានមានផលច្រើន គួរសម្តែងឲ្យពិស្តារដោយគាថាមានជាអាទិ៍ថា*

**អត្តតោ វេ បសន្នានំ** *កាលបើពួកសត្វជ្រះថ្លាក្នុង (ព្រះរត្នត្រ័យ) ថាជារបស់ប្រសើរ ដូច្នេះផង*[៦] ។

**ឯស ទេវមនុស្សានំ, សព្វកាមទទោ និធិ**

*កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តីប្រាថ្នា គ្រប់យ៉ាង*

---

[៦] *ឥតិវុត្តក. បិ. ៥៣ ទំ. ១១៨ ។*

ដល់ទេវតានិងមនុស្សទាំងឡាយ [៧] ។

ព្រះរាជា និងព្រះទេវីសូម្បីទាំង ២ អង្គនោះ ត្រាស់ប្រាប់**បុរិមកម្ម** (កម្មខាងដើមមានសេចក្តីពន្យល់ថា កម្មជាតិមុនតែមួយប៉ុណ្ណោះ) របស់ខ្លួនដោយពិស្តារយ៉ាងនេះហើយ ចាប់ពីពេលនោះមក ទ្រង់បានឲ្យសាងទានសាលា ៦ កន្លែង គឺ ត្រង់ទ្វារនគរទាំង ៤ កន្លែង ត្រង់កណ្តាលនគរ ១ កន្លែង និងត្រង់ទ្វារនិវេសន៍ ១ កន្លែង ទ្រង់ធ្វើឲ្យមាននង្គ័លលើកឡើងហើយ ទូទាំងសកលជម្ពូទ្វីប ញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ទ្រង់រក្សាសីល ធ្វើឧបោសថកម្ម ក្នុងពេលអស់ព្រះជន្ម ព្រះអង្គទាំងពីរមានសួគ៌ជាទីទៅខាងមុខ ។

**ជាតកាវសាន**

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

---

[៧] ខុទ្ទកបាឋ. បិ. ៥២ ទំ. ១៧ ។

- តទា ទេវី ពាហុលមាតា អហោសិ
*ព្រះទេវីក្នុងកាលនោះ បានមកជាពាហុលមាតា*
- រាជា បន អហមេវ អហោសឹ
*ចំណែកព្រះរាជា គឺ* **តថាគត** *នេះឯង ។*

**កុម្មាសបិណ្ឌិជាតក ចប់ ៕**

(*ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក សត្តកនិបាត គន្ធារវគ្គ កុម្មាសបិណ្ឌិជាតក បិដកលេខ ៥៩ ទំព័រ ១០៧*)

# KUMMĀSAPIṆḌI JĀTAKA

SĪLA SAMADHI PAÑÑĀ

Published by Buddhist Academy of
Paññāsāstra University of Cambodia

*Compiled by*

Kol Pheng, Ph.D.

B.E. 2564

| | |
|---|---|
| ***Books' Name*** | **KUMMĀSAPIṆḌI JĀTAKA** |
| ***Compilded by*** | **Kol Pheng, Ph.D.**<br>President of Buddhist Academy of<br>Paññāsāstra University of Cambodia (PUC) |
| ***Office of*** | Buddhist Academy of PUC |
| ***Published by*** | Buddhist Academy of PUC |
| ***Copy right*** | Buddhist Academy of PUC |
| ***Date*** | B.E. 2564<br>C.E. 2023 |

# KUMMĀSAPIṆḌA-JĀTAKA. [1]

*"Service done," etc.*—The Master told this tale while dwelling in Jetavana, concerning queen Mallikā. She was the daughter of the chief of the garland-makers of Sāvatthi, extremely beautiful and very good. When she was sixteen years of age, as she was going to a flower-garden with some other girls, she had three portions of sour gruel in a flower-basket. As she was leaving the town, she saw the Blessed One entering it, diffusing radiance and surrounded by the assembly of the Brethren: and she brought him the three portions of gruel.

The Master accepted, holding out his royal bowl. She saluted the Tathāgata's feet with her head, and taking her joy as subject of meditation, stood on one side. Observing her the Master smiled. The Venerable Ānanda wondered why the Tathāgata smiled and asked him the question. The Master told him the reason, "Ānanda, this girl will be to-day the chief queen of the Kosala king through the fruit of these portions of gruel." The girl went on to the flower-garden. [406] That very day the Kosala king fought with Ajātasattu and fled away in defeat. As he came on his horse he heard the sound of her singing, and being attracted by it he rode towards the garden. The girl's merit was ripe: so when she saw the king she came without running away, and seized at the bridle by the horse's nose. The king from horseback asked if she was married or no. Hearing that she was not, he dismounted, and being wearied with wind and sun rested for a little time in her lap: then he made her

mount, and with a great army entered the town and brought her to her own house. At evening he sent a chariot and with great honour and pomp brought her from her house, set her on a heap of jewels, anointed her and made her chief queen. From that time onward she was the dear, beloved and devoted wife of the king, possessed of faithful servants and the five feminine charms: and she was a favourite of the Buddhas. It became noised abroad through the whole city that she had attained such prosperity because she had given the three portions of gruel to the Master.

One day they began a discussion in the Hall of Truth: "Sirs, queen Mallikā gave three portions of gruel to the Buddhas, and as the fruit of that, on the very same day she was anointed queen: great indeed is the virtue of Buddhas." The Master came, asked and was told the subject of the Brethren's talk: he said, "It is not strange, Brethren, that Mallikā has become chief queen of the Kosala king by giving three portions of gruel to the omniscient Buddha alone: for why? It is because of the great virtue of Buddhas: wise men of old gave gruel without salt or oil to paccekabuddhas, and owing to that attained in their next birth the glory of being kings in Kāsi, three hundred leagues in extent": and so he told the tale of old.

---

Once upon a time when Brahmadatta was reigning in Benares, the Bodhisatta was born in a poor family: when he grew up he made a living by working for wages with a certain rich man. One day he got four portions of sour gruel from a shop, thinking, "This will do for my breakfast," and so went on to his farming-work. Seeing four paccekabuddhas coming towards Benares to collect alms,

he thought,
142.
Na kiratthi anomadassisu, pāricariyā buddhesu appikā ;
Sukkhāya aloṇikāya ca, passaphalaṃ kummāsapiṇḍiyā.

"I have these four portions of gruel, [407] what if I were to give them to these men who are coming to Benares for alms?" So he came up and saluting them said, "Sirs, I have these four portions of gruel in hand: I offer them to you: pray accept them, good sirs, and so I shall gain merit to my lasting good and welfare." Seeing that they accepted, he spread sand and arranged four seats and strewed broken branches on them: then he set the paccekabuddhas in order; bringing water in a leaf-basket, he poured the water of donation, and then set the four portions of gruel in four bowls with salutation and the words, "Sirs, in consequence of these may I not be born in a poor family; may this be the cause of my attaining omniscience." The paccekabuddhas ate and then gave thanks and departed to the Nandamūla cave. The Bodhisatta, as he saluted, felt the joy of association with paccekabuddhas, and after they had departed from his sight and he had gone to his work, he remembered them always till his death: as the fruit of this, he was born in the womb of the chief queen of Benares. His name was called prince Brahmadatta. From the time of his being able to walk alone, he saw clearly by the power of recollecting all that he had done in former births, like the reflexion of his own face in a clear mirror, that he was now born in that state because he had given four portions of gruel to the paccekabuddhas when he was a servant and going to work in that same city. When he grew up he learned all the arts at Takkasilā: on his return his father was

pleased with the accomplishments he displayed, and appointed him viceroy: afterwards, on his father's death, he was established in the kingdom. Then he married the exceedingly beautiful daughter of the Kosala king, and made her his chief queen. On the day of his parasol-festival they decorated the whole city as if it were a city of the gods. He went round the city in procession; [408] then he ascended the palace, which was decorated, and on the dais mounted a throne with the white parasol erected on it; sitting there he looked down on all those that stood in attendance, on one side the ministers, on another the brahmins and householders resplendent in the beauty of varied apparel, on another the townspeople with various gifts in their hands, on another troops of dancing-girls to the number of sixteen thousand like a gathering of the nymphs of heaven in full apparel. Looking on all this entrancing splendour he remembered his former estate and thought, "This white parasol with golden garland and plinth of massive gold, these many thousand elephants and chariots, my great territory full of jewels and pearls, teeming with wealth and grain of all kinds, these women like the nymphs of heaven, and all this splendour, which is mine alone, is due only to an alms-gift of four portions of gruel given to four paccekabuddhas: I have gained all this through them ": and so remembering the excellence of the paccekabuddhas he plainly declared his own former action of merit. As he thought of it his whole body was filled with delight. Delight melted his heart and amid the multitude he uttered two stanzas of joyous song:—

Service done to Buddhas high
   Ne'er, they say, is reckoned cheap:

Alms of gruel, saltless, dry,
   Bring me this reward to reap.

Elephant and horse and kine,
   Gold and corn and all the land,
Troops of girls with form divine:
   Alms have brought them to my hand.

[409] So the Bodhisatta in his joy and delight on the day of his parasol-ceremony sang the song of joy in two stanzas. From that time onward they were called the king's favourite song, and all sung them—the Bodhisatta's dancing girls, his other dancers and musicians, his people in the palace, the townsfolk and those in ministerial circles.

[410] After a long time had passed, the chief queen became anxious to know the meaning of the song, but she durst not ask the Great Being. One day the king was pleased with some quality of hers and said, "Lady, I will give you a boon; accept a boon." "It is well, O king, I accept." "What shall I give you, elephants, horses or the like?" "O king, through your grace I lack nothing, I have no need of such things: but if you wish to give me a boon, give it by telling me the meaning of your song." "Lady, what need have you of that boon? Accept something else." "O king, I have no need of anything else: it is that I will accept." "Well, lady, I will tell it, but not as a secret to you alone: I will send a drum round the whole twelve leagues of Benares, I will make a jewelled pavilion at my palace-door and arrange there a jewelled throne: on it I will sit amidst ministers, brahmins and other people of the city, and the sixteen thousand women, and there tell the tale." She agreed. The king had all done as he said, and then sat on the throne

amidst a great multitude, like Sakka amidst the company of the gods. The queen too with all her ornaments set a golden chair of ceremony and sat in an appropriate place on one side, and looking with a side glance she said, "O king, tell and explain to me, as if causing the moon to arise in the sky, the meaning of the song of joy you sang in your delight"; and so she spoke the third stanza:—

Glorious and righteous king,
Many a time the song you sing,
In exceeding joy of heart:
Pray to me the cause impart.

[411] The Great Being declaring the meaning of the song spoke four stanzas:—

This the city, but the station different, in my previous birth:
Servant was I to another, hireling, but of honest worth.

Going from the town to labour four ascetics once I saw,
Passionless and calm in bearing, perfect in the moral law.

All my thoughts went to those Buddhas: as they sat beneath the tree,
With my hands I brought them gruel, offering of piety.

Such the virtuous deed of merit: lo! the fruit I reap to-day
All the kingly state and riches, all the land beneath my sway.

[412] When she heard the Great Being thus fully explaining the fruit of his action, the queen said joyfully, "Great king, if you discern so visibly the fruits of charitable giving, from

this day forward take a portion of rice and do not eat yourself until you have given it to righteous priests and brahmins"; and she spoke a stanza in praise of the Bodhisatta:—

Eat, due alms remembering,
Set the wheel of right to roll:
Flee injustice, mighty king,
Righteously thy realm control.

The Great Being, accepting what she said, spoke a stanza:—

Still I make that road my own
Walking in the path of right,
Where the good, fair queen, have gone:
Saints are pleasant to my sight.

[413] After saying this, he looked at the queen's beauty and said, "Fair lady, I have told fully my good deeds done in former time, but amongst all these ladies there is none like you in beauty or charming grace: by what deed did you attain this beauty?" And he spoke a stanza:—

Lady, like a nymph of heaven,
You the crowd of maids outshine:
For what gracious deed was given
Meed of beauty so divine?

Then she told the virtuous deed done in her former birth, and spoke the last two stanzas:—

I was once a handmaid's slave
At Ambaṭṭha's royal court,
To modesty my heart I gave,
To virtue and to good report.

In a begging Brother's bowl
Once alms of rice I put;
Charity had filled my soul:
Such the deed, and lo! the fruit.

She too, it is said, spoke with accurate knowledge and remembrance of past births.

## *Note of publisher (Dr. Kol Pheng), PUC President

*It should be noted that after exchanging of each other their great deeds (merits) of the past, Queen Devi gently reminds the Great King to practice the Ten Regal Qualities (Dasa Pidha Rāja Dhamma) as follows:*

1. ***Dāna***: Sharing with populace: He is a benefactor in that he rules or work to give, not to take; he devotes himself to administering services and providing welfare and aid for the people to ensure their well-being, convenience and safety; he renders assistance to those in distress and difficulty and support those who have done well.
2. **Sīla**: Maintaining good moral conduct: He is impeccable in conduct and restrained in actions

and speech; he does only good actions and upholds his honor; he sets an example for the people, commands their respect, and he is free from any cause for contempt.

3. ***Paricāga***: Working selflessly: He is capable of sacrificing personal comfort, even his own life, for the benefit of the people and the peace and stability of the country.
4. ***Ajjava***: Working honestly: He is honest and upholds the truth; he is free of deceit and upright in his dealings; he is sincere and does not deceive the people.
5. ***Maddava***: Deporting himself with gentleness and congeniality: His bearing is not arrogant, rude, harsh or conceited; he has nobility and dignity that are based on a polite and gentle manner, inspiring devotion and loyalty but not without awe (firmness).
6. ***Tapa***: Rejecting indulgence through austerity:
He destroys defilements and craving and does not allow them to control his mind; he can restrain his mind and does not allow it to become lost in sensual pleasure and debauchery; he is simple and regular in life-style, and dedicated to the fulfillment of duty, and Practicing Uposadha (Eigh Precepts)
7. ***Akkodha***: Adhering to reason, not anger: He is not given to fiery outbursts and does not make judgment or act out of anger; but has a heart of goodwill, suppressing anger; he judges and acts righteously with a mind that is subtle and calm.

8. ***Avihimsā***: Bringing tranquility through nonviolence: He does not let his power go to his head or use it to repress his subjects; he is kind; he does not find a pretext for punishing a subject out of vindictiveness and hatred.
9. ***Khanti:*** Overcoming difficulties with patience: He endures a heavy workload and perseveres in the face of tiredness; no matter how difficult or depressing the work may be, he does not give in; no matter how much he is provoked or ridiculed, or with whatever harsh and abrasive words, he does not despair; he refuses to abandon a task that is rightfully done.
10. ***Avirodhana***: Not doing that which strays from righteousness: He does not transgress the principles of public administration that are based on the welfare, happiness and righteousness of the people and the country.

[414] So both fully declared their past deeds, and from that day they had six halls of charity built, at the four gates, in the centre of the city and at the palace-door, and stirring up all India they gave great gifts, kept the moral duties and the holy days, and at the end of their lives became destined for heaven.

---

At the end of the lesson, the Master identified the birth: "At that time the queen was the mother of

Rāhula (Yasodhara), and the king was I, myself, (**Buddha Gautama**)."

---

## Footnotes

244:1 Compare *Jātakamālā* No. 3, *Kathāsaritsāgara* No. xxvii. 79.